# I-ទីស្តីការគណៈរដ្ឋមន្ត្រី

## ១-អនុក្រឹត្យ

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៤*

**អនុក្រឹត្យលេខ ៦២ អ.ន.ក្រ**

**ស្តីពីការបង្កើតប្រតិភូបណ្តោះអាសន្ន នៃ**

**កម្មវិធីផលិតស្បៀងជាលក្ខណៈគ្រួសារ « ផ.ស.គ »**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ទស្ស៍នព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានអភិវឌ្ឍន៍ជនបទ

**សំរេច**

មាត្រា ១ : បង្កើតប្រតិភូមួយមានឈ្មោះថា « ប្រតិភូបណ្តោះអាសន្ន ផ.ស.គ » ដែលមានសមាសភាពដូចតទៅ ៖

១-ឯកឧត្តមយឹម នៃលី អនុរដ្ឋលេខាធិការអភិវឌ្ឍន៍ជនបទ ប្រធាន

២-ឯកឧត្តម ឈា សុខ អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ សមាជិក

៣-លោកស្រីរស់ ស៊ីវណ្ណា តំណាងរដ្ឋលេខាធិការកិច្ចការនារី សមាជិក

៤-លោក វ៉ែន ឈុំ តំណាងក្រសួងអប់រំយុវជន និង កីឡា សមាជិក

៥-លោកវេជ្ជបណ្ឌិត គីមអាន តំណាងក្រសួងសុខាភិបាល សមាជិក

៦-លោក ទី ច័ន្ទផល អគ្គនាយកអភិវឌ្ឍន៍ជនបទ សមាជិក

៧-លោក ទ្រី មេង ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ សហគមន៍ លេខាធិការ

មាត្រា ២ : ប្រតិភូបណ្ដោះអាសន្ន << ផ.ស.គ >> មានភារៈកិច្ចរៀបចំបែបបទផ្ទេរទាំងស្រុងនូវកម្មវិធីផលិតស្បៀង លក្ខណៈគ្រួសារ<<ផ.ស.គ>>ដែលកន្លងមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋលេខាធិការដ្ឋានកិច្ចការនារី ក្រសួងអប់រំយុវជន និង កីឡា ក្រសួងសុខាភិបាល អោយទៅរដ្ឋលេខាធិការដ្ឋានអភិវឌ្ឍន៍ជនបទគ្រប់គ្រងនិងទទួលខុសត្រូវ ។ ដោះស្រាយការងារចំពោះមុខនិងបន្តសហប្រតិបត្តិការ ជាមួយអង្គការ (UNICEF) ដែលជាម្ចាស់ជំនួយកម្មវិធី ផ.ស.គ

មាត្រា ៣ : សមាជិកប្រតិភូបណ្ដោះអាសន្ន<<ផ.ស.គ>>ត្រូវចូលរួម ប្រជុំនិងធ្វើការងារតាមការអញ្ជើញ និង ណែនាំរបស់ប្រធាន ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋានអនុរដ្ឋលេខាធិការគ្រប់ រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម លោក លោកស្រី ដែលមាននាមចែង ក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ហត្ថលេខាតទៅ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |